# ព្រះពុទ្ធនៅឯណា?

ដោយព្រះតេជគុណ

**បណ្ឌិត ក. ស្រីធម្មានន្ទ នាយកមហាថេរ**

ប្រែសម្រួលដោយ

**ភិក្ខុ សឿង ខុន្ធី**

ព.ស. ២៥៥៥ គ.ស. ២០១១

# ព្រះពុទ្ធនៅឯណា?

នេះគឺជាស្នាព្រះហស្តចុងក្រោយ របស់
ព្រះតេជគុណ បណ្ឌិត ក. ស្រីធម្មានន្ទ
នាយកមហាថេរ

១៨ មីនា ១៩១៩-៣១ សីហា ២០០៦

# បទពិចារណា

ដោយ

**ព្រះតេជគុណ បណ្ឌិត ភ. ស្រីធម្មានន្ទ**

**នាយកមហាថេរ**

*ព្រះពុទ្ធសាសនាបើកចំហរចំពោះប្រពៃណី និងទំនៀមទម្លាប់ បើប្រពៃណី និងទំនៀមទម្លាប់នោះមិនធ្វើទុក្ខទោសដល់សុខុមាលភាពរបស់អ្នកដទៃ។*

*ឋានសួគ៌មិនត្រឹមតែបើកសម្រាប់អ្នកកាន់សាសនាណាមួយទេ ថែមទាំងបើកសម្រាប់បុគ្គលម្នាក់ និងគ្រប់គ្នាដែលដឹកនាំជីវិតត្រឹមត្រូវ និងជីវិតអរិយៈ។*

*ព្រះពុទ្ធសាសនាមានកម្លាំងខ្លាំងគ្រប់គ្រាន់ ដើម្បីប្រឈមមុខទប់ទល់នឹងទស្សនៈសម័យទំនើប ដែលដាក់ការប្រកួតប្រជែងជាមួយសាសនា។*

មនុស្សបានភ្លេចថា ខ្លួនមានបេះដូង។ មនុស្សភ្លេចថា ប្រសិនបើខ្លួនប្រព្រឹត្តចំពោះពិភពលោក ប្រកបដោយចិត្តមេត្តាករុណា ពិភពលោកនឹងប្រព្រឹត្តចំពោះខ្លួន ប្រកបដោយចិត្តមេត្តាករុណាវិញ។

ការអាណិតអាសូរ និងការសម្លាប់មិនអាចនៅជាមួយគ្នាបានទេ។

(ព្រះតេជគុណនិងការសម្លាប់ដោយគ្មានការឈឺចាប់)

ការប្រើងប្រែងធ្វើការងារគឺជាតាពដែលសំណាងបំផុត។

សាវ័កពិតប្រាកដរបស់ព្រះពុទ្ធអាចបដិបត្តិសាសនានេះ ដោយគ្មានការបួជាខ្លួនចំពោះគណៈ ឬនិកាយណាមួយឡើយ។

# ព្រះពុទ្ធនៅឯណា

ជនទាំងឡាយតែងតែសួរសំនួរ តើព្រះពុទ្ធបានទៅឯណា ឬតើព្រះពុទ្ធកំពុងគង់នៅឯណា? នេះគឺជាសំនួរមួយ ដែលពិបាកឆ្លើយណាស់ សម្រាប់អ្នកដែលមិនបានអប់រំចិត្តតាមជីវិតសាសនា។ នេះគឺព្រោះតែបុគ្គលគ្រប់រូបគិតតែ ពីជីវិតក្នុងផ្លូវលោក។ ជនទាំងឡាយពិបាកយល់ពាក្យថា "ព្រះពុទ្ធ" នេះណាស់។ អ្នកផ្សព្វផ្សាយសាសនាមួយចំនួនបានខិតជិតពុទ្ធសាសនិក ហើយនិយាយថាព្រះពុទ្ធពុំមែនជាព្រះអាទិទេពទេ ព្រះអង្គគឺជាមនុស្ស។ ព្រះអង្គបានសុគតបាត់ទៅហើយ។ តើគេអាចទទួលបានអ្វីខ្លះដោយការគោរពបូជាមនុស្សស្លាប់ដូច្នេះ? ប៉ុន្តែយើងត្រូវយល់ពីនាមព្រះពុទ្ធថា **សត្ថាទេវមនុស្សានំ** មានន័យថាព្រះអង្គជាគ្រូរបស់មនុស្សនិងទេវតាទាំងឡាយ។ នៅពេលដែលទេវតាទាំងឡាយមានបញ្ហា ពួកទេវតាទាំងនោះមករកព្រះពុទ្ធ

ដើម្បីសុំជំបូន្មានពីព្រះអង្គ។ ពេលនោះទេវតាទាំងនោះប្រកាសថាសាស្តា (ព្រះពុទ្ធ) របស់គេ កំពុងមានជីវិតគង់នៅ ដូច្នេះបុគ្គលគ្រប់រូបគប្បីគោរពបូជាចំពោះព្រះអង្គជំនួសវិញ។

យោងតាមវិទ្យាសាស្ត្រថា យើងបានចំណាយពេលរាប់លានឆ្នាំ ដើម្បីអភិវឌ្ឍចិត្ត និងបញ្ញារបស់យើង។ នៅពេលដែលចិត្តរបស់ខ្លួនពុំទាន់បានចម្រើនអប់រំពេញលេញ ជនទាំងឡាយបានដឹងថាមានអំណាចមួយចំនួន ដែលធ្វើឲ្យធម្មជាតិដំណើរការ។ ដោយសារពួកគេមិនអាចយល់បានពីការប្រព្រឹត្តទៅ តាមច្បាប់ធម្មជាតិឲ្យបានច្បាស់លាស់ ទើបពួកគេចាប់ផ្តើមគិតថាពិតជាមានបុគ្គល ដែលជាអ្នកបង្កើត និងថែរក្សានូវបាតុភូតទាំងនោះ។ ដើម្បីឲ្យអ្នកដទៃយល់បាននូវបញ្ញត្តិនេះ គេបានផ្ទេរថាមពលនេះឲ្យទៅជារូបភាព ហើយបានបង្ហាញរូបភាពនោះ ដោយរូបកាយជាបដិមា

និងផ្ទាំងគំនូរទាំងឡាយ។ បាតុភូត ឬអំណាចទាំងនេះគឺ មានសារសំខាន់ ដើម្បីធ្វើឲ្យមនុស្សធ្វើអំពើល្អ កុំឲ្យ ធ្វើអាក្រក់ ហើយឲ្យរង្វាន់ដល់ពួកគេ ប្រសិនបើគេធ្វើ អំពើល្អ។ ជានិច្ចកាលយើងមានសេចក្ដីភ័យខ្លាច ក្ដី ព្រួយបារម្ភ សេចក្ដីសង្ស័យ អសន្តិសុខ ដូច្នេះយើង ត្រូវការអ្នកណាម្នាក់ ដើម្បីពឹងពាក់សម្រាក់ការការពារ ដល់យើង។ ទីបំផុតកម្លាំងនេះបានត្រូវធ្វើរូបបរិវត្ត ឲ្យ ទៅជាព្រះអាទិទេពមួយអង្គ។ ឥឡូវអ្នកខ្លះបែរជាពឹង ពាក់លើព្រះអាទិទេពសម្រាប់អ្វីៗគ្រប់យ៉ាង។ ហេតុ ដូច្នេះហើយ ទើបគេព្យាយាមណែនាំគំនិតនៃព្រលឹង អមតៈដែលឃ្លាតចាកពីលោកនេះ ហើយទៅស្ថិតនៅ ក្នុងឋានសួគ៌ជារៀងរហូត។ នោះគឺដើម្បីបំពេញនូវ តណ្ហាសម្រាប់អត្ថិភាពអមតៈនោះឯង។ ព្រះសម្មា-សម្ពុទ្ធទ្រង់ត្រាស់អ្វីៗ ដែលឧប្បត្តិកឡើងគឺស្ថិតនៅ

ក្រោមអំណាចនៃការប្រែប្រួល ទ្រុឌទ្រោម និងការបែកធ្លាយទៅវិញ។

នៅពេលយើងធ្វើការវិភាគជីវិត របស់ព្រះពុទ្ធ យើងឃើញថា ព្រះអង្គមិនដែលណែនាំព្រះអង្គផ្ទាល់ ថាជាបុត្ររបស់ព្រះអាទិទេព ឬជាសាសនទូតរបស់ព្រះក្រៅពីសាស្តាចារ្យសាសនា ដែលជាអ្នកត្រាស់ដឹងនោះទេ។ ទន្ទឹមគ្នានេះដែរ ព្រះពុទ្ធមិនត្រូវបានគេណែនាំ ថាជាអវតាររបស់ព្រះពុទ្ធមួយទៀតឡើយ។ ព្រះពុទ្ធមិនមែនបង្កើតឡើង ដោយព្រះពុទ្ធមួយអង្គផ្សេងទៀតទេ។ ដូច្នេះព្រះពុទ្ធមួយអង្គមិនមែនជាការចាប់ជាតិចេញពីព្រះពុទ្ធមួយអង្គផ្សេងទៀតឡើយ។ ព្រះអង្គគឺជាបុគ្គល ដែលបានធ្វើការងារអស់រយៈពេលយូរ ពីជាតិមួយទៅជាតិមួយ ដោយបានចម្រើន និងធ្វើនូវមហាគុណ សីលគុណ បញ្ញាគុណ ដែលយើងហៅថាបារមី។ នៅពេលដែលព្រះអង្គបានបំពេញគុណសម្បត្តិ

ល្អទាំងអស់ហើយ ព្រះអង្គក៏បានសម្រេចនូវការត្រាស់ដឹង ពោលគឺជាការយល់ដឹងសព្វគ្រប់ទូទាំងចក្រវាលទាំងអស់ ដែលប្រព្រឹត្តិទៅក្នុងលោក។ ព្រះអង្គបានរកឃើញថា គ្មានអាទិទេពណាមួយបានបង្កើតចក្រវាលទេ។

ជនទាំងឡាយសួរថា តើព្រះអង្គអាចសម្រេចការត្រាស់ដឹងដូចម្តេចកើត បើពុំមានការជួយជ្រោមជ្រែងពីអាទិទេពនោះ។ ពុទ្ធសាសនិកទាំងឡាយអះអាងថា បុគ្គលគ្រប់រូបអាចអប់រំចិត្ត ដើម្បីឲ្យយល់នូវអ្វីៗគ្រប់យ៉ាងបាន។ ពាក្យថា "មនុស្ស" មកពី "មន" និង "ឧស្ស" មានន័យថាមនុស្ស។ ពាក្យថា "មន" មានន័យថាចិត្ត។ ម្លោះហើយមនុស្សជាអ្នក ដែលអាចអភិវឌ្ឍ និងអប់រំចិត្តឲ្យបានភាពឥតខ្ចោះ។ ក្រៅពីមនុស្ស គ្មានសត្វមានជីវិតដទៃណាក្នុងលោកនេះអាចអភិវឌ្ឍចិត្ត ឲ្យដល់កម្រិតហ្នឹង សូម្បីតែពួកអាទិទេពក៏មិនអាចក្លាយជា

ព្រះពុទ្ធបានដែរ ព្រោះអាទិទេពទាំងនោះមិនអាច អភិវឌ្ឍចិត្តឲ្យដល់កម្រិតហ្នឹង។ ពួកអាទិទេព ឬទេវតាទាំងនោះមានអត្ថិភាពរុងរឿងស្ងប់ និងមានកាមលោកីយ៍ ប៉ុន្តែថាមពលនៃការគិតរបស់ពួកគេគឺនៅខ្សោយណាស់។ មានតែមនុស្សទេ ដែលអាចក្លាយជាព្រះពុទ្ធ ឬអ្នកត្រាស់ដឹងបាន។ នៅពេលដែលជនទាំងឡាយនិយាយថា ព្រះពុទ្ធមិនមែនជាព្រះអាទិទេព យើងមិនគប្បីព្យាយាមបង្ហាញភស្តុតាង ថាព្រះអង្គជាព្រះអាទិទេពទេ។ ប្រសិនបើយើងព្យាយាមបង្ហាញភស្តុតាង ដូចនេះតាមពិតពេលនោះយើងបន្ទាបបន្ថោកគំនិតនៃការត្រាស់ដឹង។ អ្នកខ្លះអះអាងថា ព្រះរបស់គេបានផ្តល់សារដល់មនុស្ស។ ប្រសិនបើសារនោះ គឺសម្រាប់មនុស្សទាំងអស់ក្នុងលោកនេះ ហេតុអ្វីបានជាព្រះអាទិទេពនោះ មិនប្រកាសសាររបស់ខ្លួនក្នុងចំណោមមហាជន ជំនួសឲ្យការលាតត្រដាងសារ

ចំពោះតែមនុស្សម្នាក់។ ព្រះពុទ្ធមិនបានលើកទឹកចិត្តឲ្យនរណាម្នាក់ជឿអ្វីមួយ ឬប្រកាសថាព្រះអង្គបានត្រូវបង្រៀនដោយអានុភាពមួយខ្ពស់ជាង ដើម្បីធ្វើដូច្នេះ។

ថ្ងៃមួយ បព្វជិតគ្រីស្តសាសនាម្នាក់បានមកជួបខ្ញុំជាមួយនឹងបរិស័ទរបស់លោកជាច្រើន ដើម្បីពិភាក្សាអំពីព្រះពុទ្ធសាសនា ហើយបានសួរថា តាមពិតទៅអ្នកអាចប្រាប់ខ្ញុំបានទេថា តើពុទ្ធសាសនិកទាំងឡាយជឿលើអ្វី? ពេលនោះខ្ញុំបានប្រាប់លោកដោយត្រង់ថាពុទ្ធសាសនិកទាំងឡាយ "មិនជឿអ្វីទេ"។ ពេលនោះលោកចង្អុលទៅសៀវភៅដែលខ្ញុំសរសេរ ដែលមានចំណងជើងថា "តើពុទ្ធសាសនិកជឿអ្វី" ហើយសួរថាហេតុអ្វីសរសេរសៀវភៅនេះ? ខ្ញុំបានប្រាប់គាត់ "ហេតុហ្នឹងហើយ ទើបបានជាខ្ញុំសរសេរសៀវភៅនេះ សម្រាប់អ្នកដើម្បីអានវា ដើម្បីឲ្យដឹង ថាតើមានអ្វីសម្រាប់ជឿឬអត់"។ "ក្នុងករណីនេះ" លោកបានសួរថា "តើអ្នក

អាចប្រាប់ខ្ញុំបានទេថា ពុទ្ធសាសនិកទាំងឡាយធ្វើអ្វី?" ខ្ញុំបានប្រាប់លោកថា ព្រះពុទ្ធបានផ្តល់ចម្លើយចំពោះសំណួរហ្នឹងរួចហើយ ព្រះអង្គបានទូន្មានយើងពីអ្វីដែលត្រូវធ្វើ។ ជំនួសឲ្យការជឿ បុគ្គលត្រូវតែប្រតិបត្តិតាមបរិយត្តិ បដិបត្តិ និងបដិវេធ។ មានរបៀបត្រូវប្រតិបត្តិបីយ៉ាង។ ដំបូងបង្អស់យើងត្រូវព្យាយាមយល់ ព្រោះយើងមិនត្រូវជឿអ្វីមួយយ៉ាងងងឹតងងល់ ដែលយើងមិនបានយល់នោះទេ។ ព្រះពុទ្ធទ្រង់ត្រាស់ថា ដំបូងយើងត្រូវតែព្យាយាមយល់សិន។

ក្នុងពុទ្ធដីការបស់ព្រះអង្គ អំពីអរិយមគ្គអង្គប្រាំបី ចំនុចទីមួយគឺសម្មាទិដ្ឋិ ការយល់ត្រូវ។ ព្រះពុទ្ធបានចាប់ផ្តើមបេសកកម្មរបស់ព្រះអង្គ គឺការផ្សព្វផ្សាយព្រះធម៌ ដោយឲ្យសាវ័កទាំងឡាយចម្រើនសម្មាទិដ្ឋិ ជាជាងសទ្ធាខ្វះបញ្ញា ឬជំនឿខ្វាក់។ បន្ទាប់ពីបានរៀនយើងទទួលបានចំណេះដឹងអំពីព្រះពុទ្ធ និងព្រះធម៌ដ៏

អស្ចារ្យនោះ។ អ្នកត្រូវប្រតិបត្តិនូវអ្វីដែលអ្នកបានរៀន។ ប្រសិនបើអ្នកមិនបានយល់ទេ អ្នកនឹងបង្កើតគំនិតយោងទៅតាមទំនើងចិត្តរបស់អ្នក។ ដំបូន្មានរបស់ព្រះអង្គឲ្យប្រតិបត្តិទៅតាមអ្វី ដែលអ្នកបានរៀនប្រកបដោយការយល់ដឹង។ បន្ទាប់ពីបានប្រតិបត្តិ អ្នកប្រទះនូវផល ពេលនោះអ្នកនឹងដឹងពិតប្រាកដ។ នេះជាវិធីសាស្ត្របីយ៉ាង ដែលព្រះពុទ្ធទ្រង់បានឲ្យរៀន ឲ្យយល់ ឲ្យប្រតិបត្តិ។ នេះជាវិធីនៅក្នុងលោកនេះ ដើម្បីកំចាត់បង់នូវសេចក្ដីទុក្ខរបស់យើង។ ឥឡូវអ្នកអាចយល់បានថា មាគ៌ារបស់ព្រះពុទ្ធ ពីការណែនាំសាសនា គឺមិនមែនស្នើសុំឲ្យយើងជឿអ្វីមួយទេ ប៉ុន្តែឲ្យយើងរៀនប្រតិបត្តិ និងធ្វើពិសោធន៍ ដើម្បីឲ្យឃើញផល។

ជាតួយ៉ាងព្រះពុទ្ធទ្រង់ត្រាស់ថា អ្នកត្រូវតែមានចិត្តសប្បុរស អ្នកត្រូវតែស្មោះត្រង់។ បន្ទាប់ពីបាន

យល់ធម៌នេះហើយ អ្នកគប្បីព្យាយាមប្រតិបត្តិតាម បន្ទាប់មកបុគ្គលគ្រប់រូបគោរពអ្នក នៅពេលដែលគេដឹងថាអ្នកមានចិត្តសប្បុរស និងស្មោះត្រង់។ គ្មាននរណាមួយចង់រំខានអ្នក ឬចោទប្រកាន់អ្នកទេ ប៉ុន្តែគេគោរពអ្នក។ ហ្នឹងហើយជាផលល្អ ដែលអ្នកជួបប្រទះ។ ទន្ទឹមគ្នានេះដែរ ព្រះពុទ្ធត្រាស់ថា អ្នកត្រូវព្យាយាមយល់ ទៅតាមកំម្រិត នៃបទពិសោធន៍របស់អ្នក។ អ្នកអាចសាកល្បងលទ្ធផល នៃការប្រតិបត្តិរបស់អ្នកផ្ទាល់។ អ្នកយល់ថា ហេតុអ្វីរឿងរ៉ាវខ្លះខុស ហើយរឿងរ៉ាវខ្លះទៀតត្រឹមត្រូវ ហើយអ្នកមិនធ្វើតាមប្រការទាំងនោះទេ ព្រោះជាបញ្ជា ឬជាបង្គាប់មកពីឋានសួគ៌។ អ្នកមានចិត្តសម្រាប់ធ្វើការគិត និងសុភ-វិនិច្ឆ័យដើម្បីយល់ដឹង។ បញ្ញា និងបទពិសោធន៍ផ្ទាល់របស់យើងល្មមគ្រប់គ្រាន់ដើម្បីយល់ដឹង ហេតុអ្វីបានជារឿងរ៉ាវខ្លះខុស ឬត្រូវ។ ឧទាហរណ៍ព្រះពុទ្ធទូន្មាន

យើងមិនឲ្យបំផ្លាញសត្វ ដែលមានជីវិតដទៃទៀត។ ព្រះអង្គមិនបានណែនាំរឿងនេះថា ជាច្បាប់សាសនាទេ ព្រោះដោយការយល់ឃើញថា មនុស្សគួរតែដឹងថា ការសម្លាប់នោះគឺជាអំពើឃោរឃៅ។ យើងមិនពិបាកយល់ថាហេតុអ្វីបានជាវាអាក្រក់ទេ ពីព្រោះនៅពេលដែលបុគ្គលដទៃចូលមក ហើយព្យាយាមសម្លាប់យើងៗពិតជាមិនចូលចិត្តវាទេ។ ព្រះអង្គត្រាស់ទៀតថា នៅពេលដែលគេបានលួចយករបស់ មានតម្លៃរបស់អ្នក តើអ្នកមានអារម្មណ៍ដូចម្ដេច? ក្នុងទំនងដូចគ្នានេះដែរ នៅពេលដែលយើងលួចទ្រព្យអ្នកដទៃ គេក៏មិនចូលចិត្តវាដែរ។ យើងមិនចាំបាច់ទទួលបញ្ជា ពីព្រះអាទិទេព ឬព្រះពុទ្ធ ឬព្រះយេស៊ូ ដើម្បយល់ដឹងនូវគំនិតធម្មតានេះទេ។ គ្រូបង្រៀនខាងសាសនាកើតក្នុងលោក ដើម្បីដាស់តឿនក្រើនរំលឹកយើង នូវអ្វីដែលយើងមិនបានអើពើ ឬក៏បានភ្លេច។ បទពិសោធន៍

និងបញ្ញារបស់អ្នកផ្ទាល់ គឺសមល្មមគ្រប់គ្រាន់ជាង សម្រាប់អ្នកដើម្បីដឹងថា ហេតុអ្វីបានជារឿងរ៉ាវមួយ ចំនួនត្រូវ ឬខុសហើយ។

ព្រះពុទ្ធទ្រង់បានទូន្មានឲ្យយើងគិត និងឲ្យយល់។ យើងមានវិចារណញ្ញាណ ដើម្បីដឹងនូវហេតុផល។ យើងមានសុភវិនិច្ឆ័យ មិនដូចសត្វដទៃ ដែលមានចិត្ត ដែរ តែមិនអាចគិតដោយហេតុផលបានទេ។ ចិត្ត របស់សត្វប្រភេទនោះនៅមានកម្រិត ដើម្បីគ្រាន់តែ រកអាហារ ជម្រកស្នាក់នៅ ការការពារ និងកាមគុណ ប៉ុណ្ណោះ។ ពួកវាមិនអាចពង្រីក ឬអភិវឌ្ឍចិត្តរបស់ ខ្លួនទៅមុខទៀតទេ។ ប៉ុន្តែមនុស្សមានចិត្តដើម្បីគិត និងយល់ដឹង រហូតដល់កម្រិតខ្ពស់បាន។ ហេតុនេះ ហើយ បានជាអ្នកវិទ្យាសាស្ត្រទាំងឡាយបានរុករក ឃើញវត្ថុជាច្រើន ដែលយើងមិនធ្លាប់ឮពីមុន។ គ្មាន សត្វណាមួយក្នុងលោកអាចអភិវឌ្ឍចិត្ត ឲ្យឈានដល់

កម្រិតហ្នឹងបានទេ។ ដូច្នេះហើយមានតែមនុស្សទេ ទើបអាចក្លាយជាព្រះពុទ្ធបាន។ មានតែដោយការអប់រំ ចិត្តរបស់ខ្លួនតែម្យ៉ាងទេ ទើបមនុស្សអាចសម្រេចការ ត្រាស់ដឹងបាន។ ព្រះពុទ្ធប្រាប់យើងឲ្យធ្វើទៅតាម បទពិសោធន៍របស់យើងផ្ទាល់។ ពេលនោះយើងអាច ឃើញផល។ សាវ័កនៃសាសនាដទៃទាំងអស់ធ្វើបដិ-សណ្ឋារៈអ្នកដទៃដោយនិយាយថា "សូមឲ្យព្រះប្រទាន ពរដល់អ្នក ពុទ្ធសាសនិកកម្រធ្វើបដិសណ្ឋារៈអ្នកដទៃ ដោយនិយាយថា សូមឲ្យព្រះប្រទានពរដល់អ្នក បែប នេះណាស់។ ប៉ុន្តែគេសូត្រថា "ពុទ្ធំ សរណំ គច្ឆាមិ" (ខ្ញុំព្រះករុណាសូមយកព្រះពុទ្ធជាពឹង)។ ប្រសិនបើ គេជឿថា គេអាចយកព្រះពុទ្ធជាទីពឹង ហេតុអ្វីបានជា គេមិននិយាយថា "សូមឲ្យព្រះពុទ្ធប្រទានពរដល់អ្នក"។ ព្រះពុទ្ធក៏ទ្រង់បានទូន្មាន ឲ្យជនទាំងឡាយនឹកឃើញ ដល់ព្រះពុទ្ធផងដែរ នៅពេលដែលគេភ័យខ្លាច។

ដូច្នេះ "តើព្រះពុទ្ធនៅឯណា" គឺជាប្រធានបទរបស់យើង។ តើយើងអាចនិយាយថា ព្រះអង្គនៅក្នុងឋានសួគ៌ ឬព្រះអង្គកំពុងនៅក្នុងព្រះនិព្វាន ឬកំពុងគង់នៅកន្លែងផ្សេងទៀតបានឬទេ? តើព្រះអង្គទ្រង់បានយាងទៅណា? យើងត្រូវចងចាំថា អ្វីៗដែលយើងសួរគឺតាមទស្សនៈផ្លូវលោកប៉ុណ្ណោះ។ បន្ទាប់ពីបានត្រាស់ដឹង ព្រះពុទ្ធទ្រង់បានបន្លឺឧទានថា "អយ-មន្តិមា ជាតិ នត្ថិទានិ បុនព្ភវោ" នេះជាជាតិចុងក្រោយរបស់តថាគតៗនឹងមិនកើតទៀតទេ។ តថាគតបានឈប់កើត ម្តងហើយម្តងទៀតក្នុងលោកនេះ ពីជាតិមួយទៅជាតិមួយ ហើយប្រទះនូវសេចក្តីទុក្ខគ្មានទីបញ្ចប់ទៀតហើយ។

កាមគុណ ឬសេចក្តីសប្បាយរីករាយ ដែលមនុស្សបានប្រសប់ជួបប្រទះ គឺគ្រាន់តែជាសេចក្តីពេញ

ចិត្តផ្អែកអារម្មណ៍បណ្តោះអាសន្ន ដែលសាបរលាបទៅវិញក្នុងអំឡុងពេលដ៏ខ្លី។ នេះបង្កើតបាននូវសេចក្តីទុក្ខឡើង។ ក្នុងពេលមានជីវិតរស់នៅ យើងជួបប្រទះសេចក្តីទុក្ខផ្លូវកាយ និងផ្លូវចិត្ត ការព្រួយបារម្ភ បញ្ហាជាច្រើន ការឈឺចុកចាប់ ភាពលំបាក ភយន្តរាយ និងសេចក្តីមិនពេញចិត្តយ៉ាងច្រើនសន្ធឹកសន្ធាប់។

ក្នុងលោកនេះ គ្មានបុគ្គលណាមួយអាចនិយាយថាគាត់ពេញចិត្តនឹងជីវិតនេះទេ។ ទាំងបុគ្គលគ្រប់រូបត្អូញត្អែរ និងរអ៊ូរអំពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត។ ដោយការយល់ឃើញនូវស្ថានភាពនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ឈប់ការកើតឡើងវិញ។ ហ្នឹងហៅថាការសង្គ្រោះ។ ការសង្គ្រោះមានន័យថា ការរំដោះចេញពីសេចក្តីទុក្ខផ្លូវកាយ និងផ្លូវចិត្ត។ ដោយមានរូបកាយឬរូបដទៃទៀតតាំងនៅ យើងមិនអាចកម្ចាត់បង់សេចក្តីទុក្ខផ្លូវកាយ និងផ្លូវចិត្តបានទេ។ ម្លោះហើយ បើយើង

មិនចង់រង់ទុក្ខទេ ប្រការដែលប្រសើរបំផុតគឺត្រូវបញ្ឈប់ការកើតនេះឯង។ យើងប្រាថ្នាចង់បានភព។ តណ្ហា និងឧបាទាននេះចាក់ឫសយ៉ាងជ្រៅ នៅក្នុងចិត្តរបស់យើង។ ប៉ុន្តែដោយសារតែតណ្ហា និងអវិជ្ជា យើងនៅតែចង់ស្ថិតនៅ ទោះបីជាមានសេចក្តីទុក្ខ បញ្ហាការឈឺចាប់ ជម្ងឺដម្កាត់ និងបញ្ហាដទៃទៀតជាច្រើនក៏ដោយ។ ឥឡូវ ចូរក្រឡេមើលនូវអ្វី ដែលកំពុងកើតឡើងនៅក្នុងលោកនេះ។ ពិភពលោកទាំងមូលគឺជាសមរភូមិ។

ប្រជាជនទូទាំងពិភពលោកបង្កើតអំពីហិង្សា ការបង្ហូរឈាម សង្គ្រាម និងការបំផ្លិចបំផ្លាញ។ សត្វតិរច្ឆានទាំងឡាយកំពុងរស់នៅ ដោយគ្មានការបង្កើតនូវបញ្ហាជាច្រើន ដោយមិនចាំបាច់ដើម្បីឲ្យរងទុក្ខដូច្នេះទេ។ នៅពេលដែលសត្វទាំងឡាយឃ្លាន ពួកវាចេញទៅក្រៅ ហើយចាប់សត្វដទៃទៀត ធ្វើជាអាហារបំបាត់សេចក្តី

ស្រែកឃ្លានរបស់វា រួចហើយទៅដេក។ ប៉ុន្តែមនុស្ស មិនអាចធ្វើឲ្យពេញចិត្ត ដោយគ្មានតណ្ហាចំពោះវត្ថុជាច្រើនឡើយ។

តណ្ហា និងឧបាទានគឺមានលក្ខណៈរឹងមាំ នៅក្នុងចិត្តរបស់យើងណាស់។ ដោយសារតែរឿងហ្នឹង ទើបសេចក្តីច្រណែនឈ្នានីស អមិត្តភាព សេចក្តីក្រោធ សេចក្តីព្យាបាទគ្នា អំពើឃោរឃៅ និងភាពអាក្រក់ជាច្រើនកើតឡើង។ សត្វដទៃទៀតពុំអាចអភិវឌ្ឍសេចក្តីឃោរឃៅរបស់វា ឲ្យឈានដល់កម្រិតហ្នឹងទេ។

មនុស្សមានសាសនា។ សាសនាមិនមែនដើម្បីគ្រាន់តែធ្វើការគោរពបូជា និងបួងសួងទេ ប៉ុន្តែត្រូវធ្វើសេវាកម្ម ដល់សត្វមានជីវិតដទៃ ដោយការជម្រុះចោលនូវគំនិតអាក្រក់មួយចំនួន ដើម្បីយើងអាចបម្រើអ្នកដទៃបាន។ លក្ខណៈបូជាទាំងឡាយរបស់សាសនាគឺ

ជាការសំខាន់ដែរ ប៉ុន្តែដោយការគោរពបូជាតែម្យ៉ាងពុំអាចអភិវឌ្ឍចិត្ត ឲ្យទទួលបានការយល់ដឹង ឬបញ្ញាបានសមរម្យទេ។ មុនការបរិនិព្វាននៃព្រះសម្មាសម្ពុទ្ធ បរិស័ទទាំងឡាយបានមកជួបជុំគ្នា មានផ្កាភ្ញី ដើម្បីថ្វាយ និងសម្តែងការគោរពចំពោះព្រះអង្គ។ ព្រះពុទ្ធស្នើសុំឲ្យពួកគេត្រលប់មកវិញ។ ព្រះអង្គទ្រង់មានពុទ្ធ-ដីកាថា ប្រសិនបើពួកគេពិតជាចង់គោរពព្រះអង្គ ជំនួសឲ្យការបូជាដោយផ្កា និងដង្វាយផ្សេងៗ ពួកគេគប្បីបដិបត្តិតាម យ៉ាងហោចនូវឱវាទមួយ ដែលផ្តល់ឲ្យដោយព្រះអង្គ។ ពេលនោះ ទើបគេពិតជាគោរពនូវព្រះពុទ្ធ។

ឥឡូវអ្នកអាចយល់នូវអ្វី ដែលព្រះពុទ្ធចង់បាន។ មាគ៌ាជីវិត តាមបែបសាសនាមួយ មិនមែនគ្រាន់តែដើម្បីបួងសួងទេ ប៉ុន្តែត្រូវធ្វើតាមដំបូន្មាន ដែលផ្តល់ឲ្យដោយព្រះអង្គ។ គ្រាមួយ ភិក្ខុមួយអង្គ នាមបក្កុលៈ

បានមកអង្គុយ នៅចំពោះព្រះភក្ត្រព្រះសម្មាសម្ពុទ្ធ ហើយគន់មើលព្រះអង្គរាល់ថ្ងៃ។ ថ្ងៃមួយព្រះពុទ្ធសួរលោកថា "តើអ្នកកំពុងធ្វើអ្វីនៅទីនេះ?" លោកនិយាយថា "នៅពេលដែលទូលបង្គំសម្លឹងមើលព្រះកាយរបស់ព្រះអង្គ វាបានផ្តល់ឲ្យទូលបង្គំ នូវសេចក្តីសុខយ៉ាងច្រើន។" ពេលនោះព្រះពុទ្ធទ្រង់មានពុទ្ធដីការ ថា "បក្កុលៈ" ដោយការមើលរូបកាយស្មោគគ្រោក កខ្វក់មិនបិតបេរនេះ តើអ្នកបានទទួលអ្វី? អ្នកកំសាន្តតែអារម្មណ៍របស់អ្នកប៉ុណ្ណោះ អ្នកមិនដែលទទួលបានចំណេះដឹង ឬបញ្ញាទេ ក្រៅពីកំសាន្តអារម្មណ៍នោះ។ អ្នកមិនអាចឃើញព្រះពុទ្ធពិតប្រាកដ តាមរយៈរូប-កាយនេះទេ។ ព្រះពុទ្ធមិនមែនរូបកាយនោះឡើយ។ បន្ទាប់មកព្រះអង្គមានពុទ្ធដីការថា "មានតែបុគ្គលដែលយល់ដឹងនូវព្រះធម៌ ដែលសម្តែងដោយព្រះពុទ្ធ ទើបឃើញព្រះពុទ្ធពិត"។ ព្រះពុទ្ធពិតកើតឡើងក្នុងចិត្ត

នៅពេលដែលយើងយល់នូវអ្វី ដែលព្រះពុទ្ធបានសម្តែង។ ត្រង់ចំនុចនេះ អ្នកអាចយល់បានថាព្រះពុទ្ធមិនមែនពិសេសអំពីរូបកាយនេះទេ។ នៅពេលអ្នកសិក្សាប្រវត្តិសាស្រ្តប្រទេសឥណ្ឌាជិត ៥០០ ឆ្នាំ គឺមានពុទ្ធបដិមា ព្រោះព្រះពុទ្ធទ្រង់មិនបានលើកទឹកចិត្តណាមួយកសាងនូវបដិមានៃខ្លួនព្រះអង្គឡើយ។ គឺជាជនជាតិក្រិចទេ ដែលបានបង្កើតនូវព្រះពុទ្ធបដិមាទាំងឡាយ និងរូបភាពនៃនិមិត្តសញ្ញាសាសនាដទៃទៀត។ ពិតណាស់ ឥឡូវរូបភាពផ្សេងៗនៃពុទ្ធបដិមាជាច្រើនបានផ្សាយទូទាំងពិភពលោក។

សាវ័ក របស់សាសនាមួយចំនួនចោទលទោសយើងថាជាអ្នកគោរពបូជារូបសំណាក។ តាមពិតគេឥតដឹងនូវអ្វីដែលពុទ្ធសាសនិកទាំងឡាយកំពុងធ្វើទេ។ ពីរបីរយឆ្នាំបន្ទាប់ពីព្រះពុទ្ធមក មានភិក្ខុល្បីល្បាញមួយអង្គនាមឧបគុប្ត។ ព្រះអង្គជាធម្មកថិកដ៏មានប្រជាប្រិយ-

ភាព។ នៅពេលដែលព្រះអង្គសម្តែងធម៌ ប្រជាជនរាប់ពាន់នាក់បានមកប្រជុំគ្នាស្តាប់។ មារមានចិត្តបាបអន់ចិត្តខ្លាំងណាស់ ព្រោះប្រជាជនកាន់តែច្រើនឡើងកំពុងក្លាយជាអ្នកកាន់សាសនា។

មារទាំងឡាយពុំមែនជាសត្វមានជីវិតទេ តែជាការរារាំង និងជាឧបសគ្គផ្នែកផ្លូវចិត្តដ៏ខ្លាំង ដែលទប់ស្កាត់បុគ្គល ពីការដឹកនាំមាគ៌ាជីវិតតាមបែបសាសនា។ មារពេលនោះត្រូវបានធ្វើបដិរូបកម្មថា ជាបុគ្គលមានចិត្តបាប។ មារនេះចាប់ផ្តើមសម្តែងអាការៈ ដែលធ្វើឲ្យមានការទាក់ទាញ ដោយការរាំច្រៀង និងធ្វើការលេងសប្បាយ អ៊ូអរ ក្អាកក្អាយនៅមុខព្រះវិហារ។ ពេលនោះអ្នកទាំងឡាយ ជាឧបាសកឧបាសិកាត្រឡប់បែរមើលមារបន្តិចម្តងៗ។ គ្មានរណាមួយស្តាប់ព្រះធម៌របស់ព្រះអង្គឡើយ។ ឧបគុថៈបានសម្រេចចិត្តប្រដៅមារនូវមេរៀនដ៏ល្បីងជូរចត់មួយ ហើយលោកក៏

និមន្តទៅមើលការសម្ដែងនោះដែរ។ នៅពេលដែលការសម្ដែងនោះបានបញ្ចប់ ឧបគុថៈនិយាយថាលោកពិតជាសរសើរការសម្ដែងនោះណាស់។ ក្នុងការសរសើរនូវការសម្ដែងរបស់អ្នក ខ្ញុំសុំដាក់កម្រងផ្កានៅលើករបស់អ្នក។ មារមានអំនួតខ្លាំងណាស់។ នៅពេលដែលឧបគុថៈដាក់កម្រងផ្កា មារដឹងថា កម្រងផ្កានោះរឹតជុំវិញករបស់ខ្លួន ដូចជាពស់ថ្លាន់។ មារព្យាយាមទាញវាចេញ តែមិនអាចទាញចេញ។ មារក៏បានចូលទៅកាន់សំណាក់សក្កទេវរាជ ស្ដេចនៃទេវតាសុំឲ្យព្រះអង្គជួយដោះកម្រងផ្កា។ សក្កទេវរាជក៏ព្យាយាមអស់ពីលទ្ធភាព តែព្រះអង្គក៏មិនអាចដោះវាចេញបានដែរ។ បន្ទាប់មកមារក៏បានទៅកាន់សំណាក់ព្រះព្រហ្ម ជាព្រះបង្កើតលោក កាលពេលនោះ សុំឲ្យព្រះព្រហ្មជួយដោះកម្រងផ្កា។ ព្រះព្រហ្មក៏ព្យាយាមដោះកម្រងផ្កាចេញ តែក៏មិនអាចដោះចេញបានដែរ។

ពេលនោះព្រហ្មបានប្រាប់មារថា មានតែបុគ្គល អ្នកដាក់កម្រងផ្កានេះទេ ទើបអាចយកវាចេញបាន។ ពេលនោះឧបគុថ្ថៈបានមានថេរដីការថា វាមិនពិបាកទេ ប៉ុន្តែខ្ញុំអាចធ្វើវាបាន ក្រោមល័ក្ខខ័ណ្ឌពីរយ៉ាង។ ទីមួយ អ្នកត្រូវសន្យាថា ក្នុងពេលអនាគត អ្នកនឹងមិនរំខានដល់សេវាកម្ម ផ្នែកសាសនារបស់យើងទេ។ មារបានយល់ព្រម។ ប្រការទីពីរគឺថាអ្នកបានឃើញព្រះពុទ្ធក្នុងឱកាសជាច្រើន អ្នកបានព្យាយាមរំខានព្រះពុទ្ធ។ អ្នកបានរស់នៅពីរបីរយឆ្នាំ បន្ទាប់ពីព្រះពុទ្ធ។ អ្នកមានឫទ្ធិអាចសម្តែងចេញជារូបកាយ។ មារនិយាយថា "ត្រូវហើយ ខ្ញុំអាចធ្វើតាមបាន ប្រសិនបើអ្នកសន្យាថាមិនគោរពខ្ញុំទេ នៅពេលដែលខ្ញុំលេចឡើងជាព្រះពុទ្ធព្រោះខ្ញុំមិនមែនជាព្រះពុទ្ធបរិសុទ្ធស្អាតស្អំទេ"។ នៅពេលនោះ ព្រះតេជគុណឧបគុថ្ថៈមានថេរដីការថា "ខ្ញុំនឹងមិនគោរពថ្វាយបង្គំអ្នកទេ"។ ប៉ុន្តែ នៅពេល

ដែលមារសម្តែងឫទ្ធិ លេចរូបឡើងជាព្រះពុទ្ធពិតប្រាកដ ព្រះតេជគុណឧបគុបៈសម្តែងការគោរព។ ពេលនោះមារបានស្រែកថា អ្នកសន្យាថាអ្នកនឹងមិនគោរពថ្វាយបង្គំខ្ញុំទេ។ ពេលនោះព្រះឧបគុបៈមានថេរដីកាថា "ខ្ញុំមិនគោរពមារទេ ខ្ញុំគោរពថ្វាយបង្គំព្រះពុទ្ធទេតើ"។

នេះជាឧទាហរណ៍ដ៏ល្អមួយ សម្រាប់ជនទាំងឡាយ ដើម្បីប្រាប់អ្នកដទៃនូវអត្ថន័យនៃការគោរពបូជាព្រះពុទ្ធរូប។ នៅពេលដែលអ្នករក្សាទុកព្រះពុទ្ធរូបហើយថ្វាយបង្គំ អ្នកក៏អាចយករូបបដិមាជាអារម្មណ៍សម្រាប់ភាវនា។ ហ្នឹងគឺមិនមែនជាការគោរពបូជារូបសំណាកទេ។ អ្នកនិមន្តព្រះពុទ្ធមកសណ្ឋិតក្នុងចិត្តរបស់អ្នកតាមរយៈនិមិត្តរូបនេះ។ វាជានិមិត្តរូបនៃសាសនា។ របៀបព្រះពុទ្ធរូបធ្វើឲ្យពេញចិត្តមនុស្សអាចយល់បាន ក្នុងឧបទ្ទវហេតុខាងក្រោម។ ក្នុង

អំឡុងសង្គ្រាមលោកលើកទី២ មេបញ្ជាការទ័ពភូមា គឺលោកអ៊ុនុបានរកឃើញព្រះពុទ្ធតូចស្អាតមួយ។ ព្រះពុទ្ធរូបតូចនោះបានធ្វើឲ្យពេញចិត្តយ៉ាងខ្លាំង។ គាត់បានផ្ញើព្រះពុទ្ធរូប ទៅឲ្យលោកឈឺតឈើលវីនស្តុន ដែលជានាយករដ្ឋមន្ត្រីនៅពេលនោះ ជាមួយនឹងលិខិតមួយ ដោយនិយាយថា "សូមរក្សាទុករូបបដិមានោះលើតុរបស់អ្នក។ នៅពេលណាអ្នកមានក្តីព្រួយបារម្ភ ឬក្តីរំខានក្នុងចិត្ត សូមក្រលេកមើលព្រះភក្ត្រនៃរូបបដិមានេះ។ ខ្ញុំជឿថាអ្នកនឹងទទួលបានឱកាស ដើម្បីធ្វើឲ្យចិត្តរបស់អ្នកស្ងប់"។

លោកនេរុ អតីតនាយករដ្ឋមន្ត្រីប្រទេសឥណ្ឌា បានត្រូវចាប់ខ្លួន ដោយរដ្ឋាភិបាលអង់គ្លេស។ នៅពេលដែលគាត់នៅក្នុងគុក លោកមានព្រះពុទ្ធរូបតូចមួយ នៅក្នុងហោប៉ៅរបស់គាត់។ លោកបានយកព្រះពុទ្ធរូបចេញពីហោប៉ៅ ព្រមទាំងក្រឡេកមើលព្រះរូប

នោះ រួចហើយគិតថា "ទោះបីជាមានរឿងរ៉ាវ បញ្ហា និងសេចក្តីទុក្ខលំបាកជាច្រើនក្នុងលោកនេះ ប្រសិនបើព្រះពុទ្ធអាចរៀបចំ ដើម្បីរក្សានូវទឹកមុខញញឹមដូច្នេះបាន ហេតុអ្វីបានជាយើងមិនធ្វើតាមមហាបុសនេះ?"

អាណាតូលហ្វ្រានស៍ ជាអ្នកប្រាជ្ញជនជាតិបារាំងម្នាក់ បានទៅទស្សនាសារមន្ទីទីក្រុងឡុងដ៍ ហើយជាលើកដំបូង ក្នុងជីវិតរបស់គាត់ៗឃើញព្រះពុទ្ធបដិមាមួយ ដោយបានឃើញពុទ្ធបដិមានេះ គាត់និយាយថា "ប្រសិនបើព្រះអាទិទេពបានចុះពីឋានសួគ៌ មកកាន់ផែនដីនេះ ព្រះអង្គគឺគ្មានអ្វីដទៃក្រៅពីរូបនេះឡើយ"។ ក៏ប៉ុន្តែរូបបដិមាគឺមិនសំខាន់ចាំបាច់ពេកទេ។ មានជនជាច្រើនអាចប្រតិបត្តិធម៌របស់ព្រះពុទ្ធ ដោយគ្មានរូបបដិមា។ វាមិនមែនដាច់ខាតថា គេត្រូវតែមានព្រះពុទ្ធរូបមួយនោះទេ។ យើងមិនគោរពបូជា យើងមិនបួងសួង

យើងមិនសុំអ្វីពីរូបបដិមានោះទេ តែយើងថ្វាយបង្គំគោរពរូបបដិមា នៃមហាបុរសខាងសាសនានេះ។

សមាជិកម្នាក់ ក្នុងចំណោមសមាជិកទាំងឡាយរបស់យើងបាននិងកំពុងរក្សាបដិមាមួយព្រះអង្គ អស់រយៈពេល ៤៥ ឆ្នាំ ក្នុងផ្ទះរបស់គាត់។ ថ្ងៃមួយ មានអ្នកផ្សព្វផ្សាយសាសនាមួយចំនួនមកប្រាប់គាត់ថា គាត់បានកំពុងគោរពបូជាបិសាច។ គាត់មិនដឹងថាឆ្លើយប្រាប់គេយ៉ាងម៉េចទេ។ នេះគឺរឿងមួយគួរឲ្យភ្ញាក់ផ្អើល ព្រោះគាត់បានគោរពបូជាអស់ ៤៥ ឆ្នាំ នូវបដិមានោះ ហើយគាត់ឥតបានដឹងនូវអ្វីដើម្បីនិយាយ នៅពេលដែលជនទាំងឡាយថ្កោលទោសវា។ នេះជាចំនុចខ្សោយ របស់ពុទ្ធសាសនិកយើងមួយចំនួន។ គេធ្វើតាមប្រពៃណីដោយការគោរពបូជា បួងសួង ធ្វើទានសូត្រធម៌ ប៉ុន្តែគេមិនបានព្យាយាមយល់នូវព្រះពុទ្ធដីកានោះឡើយ។ ឥឡូវ អ្នកអាចយល់បានថាមាន ឬមិន

មានព្រះពុទ្ធរូប ក៏អ្នកអាចប្រតិបត្តិធម៌របស់ព្រះពុទ្ធបានដែរ។ ពីព្រោះរូបកាយពុំមែនជាព្រះពុទ្ធឡើយ។

យោងតាមពុទ្ធសាសនាមហាយាន កាយរបស់ព្រះពុទ្ធមានបី គឺ សម្ភោគកាយ១ នាមកាយ១ និងធម្មកាយ១។ ព្រះអង្គបានប្រើប្រាស់ទាំងសម្ភោគកាយទាំងនាមកាយ សម្រាប់ឆាន់ សឹង និមន្តដើរ មានពុទ្ធដីកា មានពុទ្ធដីកាឲ្យដំបូន្មាន និងសម្ដែងធម៌។ សកម្មភាពទាំងអស់នេះ ព្រះអង្គបានប្រើប្រាស់រូប-កាយធម្មតា។ នៅពេលព្រះពុទ្ធបរិនិព្វានទៅ កាយទាំងពីនេះក៏បានបាត់បង់ទៅដែរ ប៉ុន្តែធម្មកាយ ឬកាយគឺព្រះធម៌របស់ព្រះពុទ្ធ មិនចេះបាត់បង់ឡើយ។ តាមពុទ្ធសាសនា និកាយមហាយានថា ព្រះពុទ្ធអាមីតាភៈស្ថិតនៅក្នុងឋានសុខ ឈ្មោះទឹកដីបរិសុទ្ធ។ ជនទាំងឡាយ ដែលសូត្ររំលឹកនាមព្រះអង្គ ប្រកបដោយក្ដីគោរព និងអ្នកដែលគោរពបូជាព្រះអង្គនឹង

បានកើតក្នុងឋានសុខនោះដែរ រួចហើយក្រោយមក មានឱកាស ដើម្បីបានសម្រេចព្រះនិញ្វាន។ យោង តាមបែបផែននៃការគិត និងជំនឿរបស់គេ ទស្សនៈ ផ្តល់នូវក្តីសង្ឃឹម និងជំនឿទុកចិត្តថា ព្រះពុទ្ធគឺកំពុង មានព្រះជន្មគង់នៅ រហូតដល់សត្វគ្រប់រូបបាន សម្រេចនូវការសង្គ្រោះចុងក្រោយ។

ព្រះពុទ្ធទ្រង់បានសម្តែងថា "ព្រះធម៌តាំងនៅជា រៀងរហូត នៅក្នុងលោកនេះ មិនថាព្រះពុទ្ធកើតឡើង ឬអត់នោះទេ"។ នៅពេលដែលព្រះពុទ្ធមួយអង្គកើត ឡើង ព្រះអង្គដឹងថាជនទាំងឡាយបានភ្លេចនូវធម៌ពិត។ ព្រះពុទ្ធទ្រង់បានមានពុទ្ធដីកាថា "ធម៌ដែលតថាគតបាន យល់ដឹងនេះមិនមែនជាធម៌ថ្មី ដែលបង្កើតឡើងដោយ តថាគតឡើយ"។ ធម៌នេះបានស្ថិតនៅជានិច្ច ប៉ុន្តែ មនុស្សបានកាត់យល់ខុស ដោយបានបង្កើតទស្សនៈ ខុស យោងតាមការស្រមើស្រមៃរបស់គេផ្ទាល់ ហើយ

បានធ្វើឲ្យកង្វល់ដល់ភាពបរិសុទ្ធ នៃព្រះធម៌ទាំងស្រុង។ សូម្បីតែព្រឹត្តិការណ៍សព្វថ្ងៃក៏ដោយ ២៥០០ ឆ្នាំ បន្ទាប់ពីព្រះពុទ្ធបានលាតត្រដាង នូវសច្ចភាពថាជាធម៌។ ជនទាំងឡាយ កំពុងធ្វើប្រការដែលខុសឆ្គង ក្នុងប្រទេសជាច្រើនក្នុងនាមនៃព្រះពុទ្ធ។ វាមិនមែនមានន័យថា គេពិតជាធ្វើតាមពាក្យទូន្មានរបស់ព្រះពុទ្ធ ប៉ុន្តែគេបញ្ចូលការប្រតិបត្តិ តាមបែបប្រពៃណីវប្បធម៌ លាយឡំជាមួយនឹងព្រះពុទ្ធសាសនា ហើយណែនាំវាថាជាព្រះពុទ្ធសាសនា។ ក្នុងនាមយើងជាពុទ្ធសាសនិក យើងត្រូវព្យាយាមរៀននូវអ្វី ដែលព្រះពុទ្ធទ្រង់បានសម្តែងនោះ ដើម្បីស្វែងរកនូវការសង្គ្រោះរបស់យើង។

ជនទាំងឡាយសួរថា តើព្រះពុទ្ធនៅឯណា? ដើម្បីប្រតិបត្តិព្រះពុទ្ធសាសនា វាមិនចាំបាច់សម្រាប់យើង ដើម្បីដឹងថាព្រះពុទ្ធនៅឯណា ឬព្រះអង្គនិមន្តទៅណានោះទេ។ ជាតួយ៉ាង យើងមានអគ្គិសនីដែល

បានរកឃើញដោយនរណាម្នាក់។ តើវាចាំបាច់សម្រាប់យើងដឹងនូវបុគ្គល ដែលរកឃើញអគ្គិសនីថាគាត់នៅឯណា មកពីប្រទេសណា ហើយគាត់ឈ្មោះអ្វីដូច្នេះឬ? កាតព្វកិច្ចរបស់យើងគឺដើម្បីធ្វើការប្រើប្រាស់នូវអគ្គិសនី។ ជាថ្មីម្តងទៀត អ្នកដែលបានរកឃើញអាតូម ឬថាមពលបរមាណូ អាចប្រើប្រាស់ថាមពលបរមាណូនេះ សម្រាប់គោលបំណងសាងសង ឬបំផ្លាចបំផ្លាញ។ ដូច្នេះវាជាកាតព្វកិច្ចរបស់យើង ដើម្បីប្រើ-ប្រាស់នូវថាមពលនេះ ក្នុងផ្លូវដ៏ត្រឹមត្រូវសមរម្យ។ តាមពិតទៅ មិនចាំបាច់ដឹងថា នរណាជាអ្នករកឃើញនូវថាមពលអាតូមនេះទេ។ មនុស្សបានរកឃើញរបៀបផលិតកុំព្យូទ័រ និងទូរទស្សន៍ ហើយបានធ្វើវាឡើង ប៉ុន្តែមិនចាំបាច់សម្រាប់យើង ដើម្បីស្គាល់ឈ្មោះអ្នកផលិត និងព័ត៌មានពិស្តារអំពីវត្ថុទាំងនោះឡើយ តួនាទីរបស់យើង គឺត្រូវប្រើប្រាស់វាប៉ុណ្ណោះ។

ក្នុងទំនងដូចគ្នានេះដែរ សូមកុំសួរថា តើព្រះពុទ្ធនៅឯណា ឬព្រះអង្គបាននិមន្តទៅណាធ្វើអ្វី។ ប្រសិនបើព្រះធម៌ អ្វីដែលព្រះអង្គទ្រង់បានសម្តែង គឺពិតអាចរកបាន និងមានប្រសិទ្ធភាព ហេតុអ្វីចាំបាច់ត្រូវដឹងថា ព្រះអង្គនៅឯណា។ ព្រះពុទ្ធទ្រង់មិនដែលមានពុទ្ធដីកាថា ព្រះអង្គអាចបញ្ជូនយើងទៅឋានសួគ៌ ឬឋាននរកទេ។ ព្រះពុទ្ធអាចប្រាប់អ្វីត្រូវធ្វើ និងអ្វីមិនត្រូវធ្វើ ដើម្បីទទួលការសង្គ្រោះរបស់យើង ហ្នឹងគឺជាប្រការម្យ៉ាង ដែលព្រះអាចធ្វើបាន។ ព្រះអង្គមិនអាចធ្វើអ្វីៗ សម្រាប់អ្នកទាំងអស់គ្នាបានទេ។ កាតព្វកិច្ចអ្នកទាំងអស់គ្នា គឺដើម្បីប្រតិបត្តិតាមអ្វី ដែលព្រះពុទ្ធបានទូន្មានយើង។

អ្នកដទៃនិយាយថា ព្រះអាទិទេពអាចលាងបាបទាំងឡាយ ដែលយើងបានប្រព្រឹត្តធ្វើ។ ព្រះពុទ្ធទ្រង់មិនដែលមានពុទ្ធដីកាថា បាបត្រូវបានបង្កើតឡើងដោយ

បុគ្គលម្នាក់ ហើយវាត្រូវបានលាងជម្រះ ដោយបុគ្គលម្នាក់ផ្សេងទៀតទេ។ ទាំងព្រះពុទ្ធ ទាំងព្រះអាទិទេព មិនអាចធ្វើដូច្នេះបានទេ។ នៅពេលដែលបុគ្គលម្នាក់ហៀបនឹងស្លាប់ ហើយនិយាយថា គាត់ជឿលើព្រះអាទិទេព តើបន្ទាប់មករឿងរ៉ាវអាក្រក់ទាំងឡាយ ដែលគាត់បានប្រព្រឹត្ត ព្រះអាចលាងបាបរបស់គាត់បានឬទេ? ជាឧទាហរណ៍ ប្រហែលអ្នកមានអារម្មណ៍ឆេវឆាវ ហើយអ្នកបានដឹងថាខុស ប៉ុន្តែអ្នកមិនដឹងពីរបៀបកម្ចាត់បង់វាចោលទេ។ ដូច្នេះអ្នកទៅរកព្រះអាទិទេព ហើយបួងសួង សុំឲ្យព្រះអាទិទេពយកអំពើឃោរឃៅចេញពីចិត្តរបស់អ្នក តើអ្នកគិតថាមានព្រះណាមួយអាចធ្វើដូច្នេះបានឬទេ?

អ្នកអាចទៅនមស្សការព្រះពុទ្ធ ហើយសុំឲ្យព្រះអង្គលាងជម្រះនូវអំពើឃោរឃៅរបស់អ្នក ប៉ុន្តែព្រះពុទ្ធក៏មិនអាចយកវាចេញបានដែរ។ ព្រះពុទ្ធអាចប្រាប់អ្នក

ពីរបៀបកម្ចាត់នូវសេចក្ដីក្រោធ ដោយសេចក្ដីព្យាយាមរបស់អ្នកផ្ទាល់តែប៉ុណ្ណោះ។ គ្មានបុគ្គលណាមួយជួយអ្នកបាន ក្រៅពីខ្លួនអ្នក តាមរយៈការយល់ដឹងរបស់អ្នកទេ។ ខ្លួនអ្នកផ្ទាល់ត្រូវតែដឹងថា "សេចក្ដីក្រោធគឺមានគ្រោះថ្នាក់ អាចបង្កើតឲ្យមានការទាស់ទែង បញ្ហាសេចក្ដីលំបាក ក្ដីមហន្តរាយ និងសេចក្ដីរំខានជាច្រើនដល់អ្នកដទៃ។ អាត្មាអញត្រូវតែព្យាយាមកាត់បន្ថយសេចក្ដីក្រោធ ដោយការប្រើកម្លាំងចិត្តអាត្មាអញ ហើយបង្កើតនូវការតាំងចិត្តដ៏មាំ ដើម្បីដកនូវសេចក្ដីក្រោធចេញពីចិត្ត"។ ដូច្នេះ ព្រះពុទ្ធ ឬព្រះអាទិទេពមិនអាចលាងជម្រះបាបទាំងឡាយ ដែលយើងធ្វើបានទេ មានតែយើងខ្លួនឯងទេ ទើបធ្វើដូច្នេះបាន។ មានដំបូន្មានមួយ ផ្ដល់ដោយព្រះសម្ពុទ្ធ។ ប្រសិនបើនរណាមួយបានប្រព្រឹត្តិអំពើអាក្រក់ ឬកម្មអាក្រក់ គេមិនអាចកម្ចាត់បង់នូវផលបាបនោះ ដោយការបួង

សួង ចំពោះព្រះអាទិទេព ឬព្រះពុទ្ធបានទេ។ ប៉ុន្តែ នៅពេលដែលគេដឹងថា គេបានធ្វើអំពើអាក្រក់ ពេល នោះគេត្រូវឈប់ធ្វើអំពើអាក្រក់តទៅទៀត។ អ្នកត្រូវ ធ្វើការប្តេជ្ញាចិត្តឲ្យមាំនៅក្នុងចិត្ត ដើម្បីធ្វើកម្មល្អឲ្យ បានច្រើនឡើងៗ។ នៅពេលដែលអ្នកធ្វើកុសល បានច្រើនឡើងៗ ផលនៃអំពើអាក្រក់ ដែលអ្នកបាន ធ្វើពីមុនអាចត្រូវបានកម្ចាត់បង់ ដោយកុសលកម្ម នោះឯង។

ជាតួយ៉ាងអង្គុលិមាល ឃាតករដែលបានសម្លាប់ មនុស្សជិតមួយពាន់នាក់។ នៅពេលដែលព្រះពុទ្ធ ទ្រង់បានដឹងដូច្នេះ ព្រះអង្គបានយាងទៅជួបអង្គុលិ-មាល។ អង្គុលិមាលចង់ធ្វើគត់ព្រះពុទ្ធ ព្រោះគាត់ បានសម្លាប់មនុស្សយកម្រាមដៃបាន ៩៩៩ រួចហើយ។ បំណងរបស់គាត់ ត្រូវសម្លាប់មនុស្សមួយពាន់នាក់ ដូច្នេះគាត់សប្បាយចិត្តណាស់ នៅពេលបានជួប

ព្រះពុទ្ធ ហើយក៏បានព្យាយាមចាប់ព្រះអង្គ។ នាឱកាសនោះ ព្រះពុទ្ធទ្រង់បានសម្ដែងឬទ្ធិបន្តិចបន្តួច។ ដោយបានដឹងថា ពិបាកគ្រប់គ្រងមនុស្សប្រភេទនេះ ដោយការសម្ដែងធម៌ ព្រះពុទ្ធទ្រង់បានយាងតាមធម្មតាហើយទុកឲ្យអង្គុលិមាលរត់តាម។ ទោះបីជាអង្គុលិមាលរត់បានជិត ៦ គីឡូម៉ែត្រក៏ដោយ ក៏គាត់មិនអាចមកជិតព្រះពុទ្ធបានដែរ។ ពេលនោះគាត់បានឲ្យព្រះពុទ្ធឈប់ ហើយព្រះពុទ្ធបានជ្រាបថា នេះជាពេលដែលព្រះអង្គត្រូវសម្ដែងធម៌ ប្រោសអង្គុលិមាលហើយ។ ព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា "តថាគតបានឈប់រួចហើយ អ្នកជាបុគ្គលម្នាក់ដែលនៅរត់"។ អង្គុលិមាលនិយាយថា "តើអ្នកអាចនិយាយថា អ្នកឈប់ដូចម្ដេច ខ្ញុំបានឃើញអ្នកកំពុងដើរ"។ ព្រះពុទ្ធទ្រង់បានតបថា "តថាគតបានឈប់ មានន័យថាតថាគតបានឈប់សម្លាប់ ឬបំផ្លាញជីវិតសត្វដទៃ

ហើយ។ អ្នកជាបុគ្គលដែលកំពុងរត់ មានន័យថា អ្នកនៅកំពុងប្រព្រឹត្តអំពើអាក្រក់។ ប្រសិនបើអ្នកឈប់រត់ពេលនោះអ្នកអាចចាប់តថាគតបាន។ ពេលនោះអង្គុលិមាលនិយាយថា ខ្ញុំមិនអាចយល់នូវអ្វី ដែលអ្នកនិយាយទេ″។ ពេលនោះព្រះពុទ្ធទ្រង់មានពុទ្ធដីកាថា ‶តថាគតបានឈប់សម្លាប់ ឯអ្នកឯងវិញនៅតែធ្វើការសម្លាប់ នុ៎ះគឺអត្ថន័យនៃការរត់។ អ្នកកំពុងរត់ក្នុងសំសារៈ។ ពេលនោះអង្គុលិមាលបានដឹងថា ខ្លួនខុសហើយបានសម្រេចចិត្តដើរតាមព្រះអង្គ និងបានបួសជាភិក្ខុមួយអង្គ រួចហើយចាប់ធ្វើភាវនា។ ក្រោយមកលោកបានសម្រេចជាព្រះអរហន្ត និងបានសម្បត្តិសុខក្នុងព្រះនិព្វាន។ កម្មអាក្រក់មិនបានមានឱកាសហុចផលឲ្យលោកឡើយ។ លោកបន្តធ្វើឲ្យកុសលកម្មចម្រើនឡើង ហើយអកុសលកម្មឥតមានឱកាសឲ្យផលដល់លោកឡើយ។ ហ្នឹងហើយគឺអ្វីដែលព្រះពុទ្ធ

មានដីកា។ ព្រះពុទ្ធទ្រង់បានបង្រៀនវិធីសាស្ត្រនេះ ដើម្បីជម្នះនូវផលកម្មអាក្រក់ មិនមែនដោយការបួងសួងចំពោះអាទិទេពណាមួយទេ តែដោយការធ្វើអំពើជាកុសលចម្រើនឡើងៗ។

ប្រសិនបើខ្ញុំនិយាយថា ព្រះពុទ្ធកំពុងមានព្រះជន្មគង់នៅផ្នែកណាមួយ នៃសកលលោកជារូបកាយ វាជំទាស់ទៅនឹងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ។ម្យ៉ាងវិញទៀត ប្រសិនបើខ្ញុំនិយាយថា ព្រះពុទ្ធមិនកំពុងគង់នៅផ្នែកណាមួយ នៃសកលលោកជារូបកាយទេ ជនទាំងឡាយមិនសប្បាយចិត្តទេ ព្រោះគេមានសេចក្តីប្រាថ្នាចំពោះភព ដែលមិនអាចធ្វើឲ្យស្កប់ចិត្តបានឡើយ។ ម្លោះហើយគេនិយាយថា វាសូន្យទទេ។ វាមិនមែនសូន្យទទេនោះទេ វាជាការបញ្ចប់នូវសេចក្តីទុក្ខផ្លូវកាយ និងផ្លូវចិត្ត និងធ្វើឲ្យជាក់លាក់ច្បាស់នូវសុខនៃព្រះនិព្វាន ឬការសង្គ្រោះ។ ម្យ៉ាងវិញ

ទៀត មានជនមួយចំនួនពិតជាត្រូវការរូបនៃព្រះពុទ្ធរូប ដើម្បីធ្វើចិត្តរបស់គេស្ងប់ កាត់បន្ថយនូវភាពតានតឹង សេចក្ដីភ័យខ្លាច និងសេចក្ដីព្រួយបារម្ភ។ ទោះយ៉ាងណាក៏ដោយ វាមិនត្រឹមត្រូវ សម្រាប់យើង ដើម្បីនិយាយថា ព្រះពុទ្ធកំពុងមានព្រះជន្មគង់នៅ ឬអត់។ ប្រសិនបើធម៌ ឬព្រះពុទ្ធដីការបស់ព្រះពុទ្ធនៅមានសម្រាប់យើង ដើម្បីធ្វើឲ្យជាក់លាក់ដល់សេចក្ដីស្ងប់ សេចក្ដីពេញចិត្ត ក្នុងជីវិតរបស់យើងនោះ គឺវាល្មមគ្រប់គ្រាន់សម្រាប់យើងហើយ ចូរយើងធ្វើការពិចារណាទៅលើគ្រូពេទ្យ ដែលបានរកឃើញនូវឱសថដ៏មានប្រសិទ្ធិភាពមួយ។ ប្រសិនបើថ្នាំអាចរកបាន ប្រសិនបើវាអាចព្យាបាលជម្ងឺបាន តើវាចាំបាច់សម្រាប់យើងដើម្បីដឹងថា តើគ្រូពេទ្យនោះនៅឯណា ឬគាត់កំពុងរស់នៅឯណាដែរឬអត់? រឿងសំខាន់គឺត្រូវព្យាបាលជម្ងឺរបស់យើង ដោយការលេបថ្នាំនោះ។ តាមទំនង

ដូចគ្នាដែរ ធម៌របស់ព្រះសម្មាសម្ពុទ្ធគឺមានច្រើនល្មម គ្រប់គ្រាន់សម្រាប់យើង ដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខរបស់យើងបានហើយ។ ព្រះពុទ្ធបានផ្តល់សិទ្ធិឲ្យយើងចេះគិតដោយសេរី ដើម្បីឲ្យដឹងថា តើរឿងរ៉ាវមួយគឺខុស ដោយការប្រើសុភវិនិច្ឆ័យរបស់យើង ឬការឲ្យហេតុផលសម្រាប់យើង ដើម្បីយល់នូវធម្មជាតិពិតនៃសភាវធម៌ទាំងឡាយ ដែលកើតមានឡើង។

ម្យ៉ាងវិញទៀត គ្មានអ្វីមួយនៅក្នុងផ្ទៃកនៃចក្រវាលដែលឋិតនៅ គ្មានការប្រែប្រួល គ្មានការពុកផុយ និងគ្មានបែកធ្លាយឡើយ ព្រោះថារាល់របស់ទាំងនេះគឺជាការផ្សំនៃធាតុ ថាមពល និងថាមពលផ្លូវចិត្ត និងថាមពលនៃអំពើកម្ម។ ហេតុនេះ ថាមពល ធាតុ ថាមពលផ្លូវចិត្ត និងថាមពលនៃអំពើកម្មនោះមិនអាចស្ថិតនៅជារៀងរហូត ដោយគ្មានការប្រែប្រួលឡើយ។ ប្រសិនបើអ្នកអាចយល់ចំនុចនេះបាន ពេលនោះធម៌

របស់ព្រះសម្ពុទ្ធនឹងជួយអ្នកឲ្យយល់ ពីរបៀបប្រឈមមុខទៅនឹងបញ្ហា និងសេចក្តីលំបាកទាំងឡាយរបស់អ្នក ដើម្បីជម្នះនូវសេចក្តីទុក្ខរបស់យើងបាន។ ពុំនោះទេ យើងនឹងត្រូវប្រឈមមុខ ចំពោះសេចក្តីទុក្ខផ្លូវកាយ និងផ្លូវចិត្ត សេចក្តីចង្អៀតចង្អល់ និងសេចក្តីតូចចិត្តជាក់ជាមិនខាន។ យើងត្រូវប្រព្រឹត្តធ្វើអ្វីៗគ្រប់យ៉ាង ប្រកបដោយគតិបណ្ឌិត ដើម្បីកម្ចាត់បង់នូវបញ្ហាទាំងឡាយរបស់យើង។ វាពិបាកសម្រាប់យើង ដើម្បីបំបាត់សេចក្តីទុក្ខងាយៗ ដោយការបួងសួង ការគោរពបូជា ចំពោះបុគ្គលណាមួយទេ ប៉ុន្តែតាមរយៈការយល់ដឹង ពីធម្មជាតិនៃបញ្ហាសេចក្តីលំបាក របស់យើងៗនឹងអាចកម្ចាត់នូវបញ្ហាបែបនេះបាន។

ជនទាំងឡាយសួរថា តើព្រះពុទ្ធទ្រង់បានយាងទៅណា? ប្រសិនបើគេនិយាយថា ព្រះអង្គទ្រង់បានយាងចូលនិព្វាន នៅពេលនោះគេគិតថា និព្វានជា

កន្លែងមួយ។ និញ្វានមិនមែនជាកន្លែង សម្រាប់ធ្វើដំណើរទៅទេ វាជាសភាពចិត្ត ដែលគេត្រូវធ្វើឲ្យសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់ការសង្គ្រោះចុងក្រោយរបស់យើង។ យើងមិនអាចនិយាយថា ទ្រង់បានយាងទៅកន្លែងណាមួយ ឬព្រះពុទ្ធកំពុងគង់ធរមាននៅទេ តែត្រូវថា ព្រះអង្គសោយសុខនៃនិញ្វានឬ ទិសដៅចុងក្រោយនៃជីវិត។ ដូច្នេះ ចម្លើយដែលប្រសើរបំផុតចំពោះសំនួរថា "តើព្រះពុទ្ធនៅឯណា? គឺព្រះពុទ្ធស្ថិតនៅក្នុងចិត្តរបស់អ្នក ដែលបានធ្វើឲ្យជាក់ច្បាស់នូវបរមត្ថធម៌ ឬបរមត្ថសច្ចៈហ្នឹងឯង។

# អំពីអ្នកនិពន្ធ

ព្រះតេជគុណ បណ្ឌិត ក. ស្រីធម្មានន្ទ នាយកមហាថេរ បាន ចូលរួមការផ្សព្វផ្សាយព្រះពុទ្ធសាសនា អស់រយៈពេល ៥៤ ឆ្នាំ ។ ព្រះអង្គបានប្រសូត្រនៅប្រទេសស្រីលង្កា នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩១៩។ ពេលព្រះអង្គមានព្រះជន្ម ១២ វស្សា ព្រះអង្គបានបួសជាសាមណេរ និង មាននាមថា ធម្មានន្ទ មានន័យថា "បរមសុខនៃព្រះធម៌" ក៏ដូចជានាម ទីមួយ បន្ទាប់ពីនាមនៅ ភូមិ គឺ កិរិន្ទ ។

ព្រះជន្ម ២៦ វស្សា ព្រះអង្គបានបញ្ចប់ការសិក្សាពី វិទ្យាលង្ការ បរិវេណវិទ្យាល័យ នៅទីក្រុងកូឡុំបូ មានកម្រិតសញ្ញាបត្រ ឌីប្លូមភាសា បាលី និងសំស្ក្រឹត ទស្សនវិជ្ជាពុទ្ធសាសនា និងព្រះត្រៃបិដក ។ ព្រះអង្គ បានបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅសាកលវិទ្យាល័យពារាណសី ហិណ្ឌូ នៅប្រទេសឥណ្ឌាភាគខាងជើង រយៈពេល ៤ ឆ្នាំ និងបានបញ្ចប់ ថ្នាក់អនុបណ្ឌិត ទស្សនវិជ្ជាឥណ្ឌា នៅក្នុងឆ្នាំ ១៩៤៩ ។

នៅក្នុងឆ្នាំ ១៩៥២ ព្រះអង្គបានត្រូវនិមន្តមកប្រទេសម៉ាឡេស៊ី ដើម្បីគង់នៅវត្តវិហារពុទ្ធសាសនា នៅប្រិកហ្វីល ទីក្រុងកូឡាឡាំពួរ ដើម្បីបង្រៀនព្រះពុទ្ធសាសនា ។ នៅក្នុងឆ្នាំ ១៩៦២ ព្រះអង្គបានបង្កើត សមាគមពុទ្ធសាសនទូត (BMS) សម្រាប់ការងារធម្មទូតដែលបានរៀប ចំបន្ថែមទៀត នៅក្នុងប្រទេសម៉ាឡេស៊ី ។ ក្រោមសមាគមពុទ្ធសាសន-ទូត ព្រះអង្គបានសរសេរកូនសៀវភៅ និងសៀវភៅជាច្រើន ស្តីពីព្រះពុទ្ធ សាសនា។ ព្រះអង្គបានសរសេរសៀវភៅ ៧០ ក្បាល ហើយសៀវភៅ ទាំងនេះបានបកប្រែ មិនតិចជាង ១៦ ភាសា ទូទាំងពិភពលោក ។

នៅឆ្នាំ ១៩៦៥ ព្រះតេជគុណ ធម្មានន្ទ បានត្រូវតែងតាំងជាសង្ឃនាយក នៃប្រទេសម៉ាឡេស៊ី និងសិង្ហបូរី ។

ព្រះអង្គបានសុគត នៅក្នុងព្រះជន្មាយុ ៨៧ ព្រះវស្សា នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ ជាថ្ងៃទិវាបុណ្យឯករាជ្យជាតិរបស់ប្រទេសម៉ាឡេស៊ី នៅក្នុងទីក្រុងកូឡាឡាំពួរ ។

“ជនទាំងឡាយតែងតែសួរសំនួរ តើព្រះពុទ្ធបានទៅឯណា ឬតើព្រះពុទ្ធកំពុងគង់នៅឯណា? នេះគឺជាសំនួរមួយ ដែលពិបាកឆ្លើយណាស់ សម្រាប់អ្នកដែលមិនបានអប់រំចិត្តតាមជីវិតសាសនា។ នេះគឺព្រោះតែ បុគ្គលគ្រប់រូបគិតតែពីជីវិតក្នុងផ្លូវលោក។”

- ព្រះតេជគុណ បណ្ឌិត ក. ស្រីធម្មានន្ទ

# ព្រះពុទ្ធនៅឯណា

“ប្រសិនបើខ្ញុំនិយាយថា ព្រះពុទ្ធកំពុងមានព្រះជន្មគង់នៅផ្នែកណាមួយ នៃសកលលោកជារូបកាយ វាជំទាស់ទៅនឹងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ។ ម្យ៉ាងវិញទៀត ប្រសិនបើខ្ញុំនិយាយថា ព្រះពុទ្ធមិនកំពុងគង់នៅផ្នែកណាមួយ នៃសកលលោកជារូបកាយទេ ជនទាំងឡាយមិនសប្បាយចិត្តទេ ព្រោះគេមានសេចក្ដីប្រាថ្នាចំពោះភពដែលមិនអាចធ្វើឲ្យស្កប់ចិត្តបានឡើយ។ ម្ល៉ោះហើយគេ

និយាយថា វាសូន្យទទេ។ វាមិនមែនសូន្យទទេនោះទេ វាជាការបញ្ចប់នូវសេចក្ដីទុក្ខផ្លូវកាយ និងផ្លូវចិត្ត និងធ្វើឲ្យជាក់លាក់ច្បាស់នូវសុខនៃព្រះនិព្វាន ឬការសង្គ្រោះ។ ម្យ៉ាងវិញទៀត មានជនមួយចំនួនពិតជាត្រូវការរូបនៃព្រះពុទ្ធរូប ដើម្បីធ្វើចិត្តរបស់គេស្ងប់ កាត់បន្ថយនូវភាពតានតឹងសេចក្ដីភ័យខ្លាច និងសេចក្ដីព្រួយបារម្ភ។ ទោះយ៉ាងណាក៏ដោយ វាមិនត្រឹមត្រូវ សម្រាប់យើង ដើម្បីនិយាយថា ព្រះពុទ្ធកំពុងមានព្រះជន្មគង់នៅ ឬអត់។ ប្រសិនបើធម៌ ឬព្រះពុទ្ធដីការបស់ព្រះពុទ្ធនៅមានសម្រាប់យើង ដើម្បីធ្វើឲ្យជាក់លាក់ដល់សេចក្ដីស្ងប់សេចក្ដីពេញចិត្ត ក្នុងជីវិតរបស់យើងនោះ គឺវាល្មមគ្រប់គ្រាន់សម្រាប់យើងហើយ ចូរយើងធ្វើការពិចារណាទៅលើគ្រូពេទ្យ ដែលបានរកឃើញនូវឱសថដ៏មានប្រសិទ្ធិភាពមួយ។ ប្រសិនបើថ្នាំអាចរកបាន ប្រសិនបើវាអាចព្យាបាលជម្ងឺបាន តើវាចាំបាច់សម្រាប់យើងដើម្បីដឹងថាតើគ្រូពេទ្យនោះនៅឯណា ឬគាត់កំពុងរស់នៅឯណាដែរឬអត់? រឿងសំខាន់គឺត្រូវព្យាបាលជម្ងឺរបស់យើង ដោយ

ការលេបថ្នាំនោះៗ តាមទំនងដូចគ្នាដែរ ធម៌របស់ព្រះសម្មាសម្ពុទ្ធគឺមានច្រើនល្មមគ្រប់គ្រាន់ សម្រាប់យើងដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខរបស់យើងបានហើយៗ

**ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធដោយ**

- ភិក្ខុ **អ៊ុំ សត្ថា** សមណនិស្សិតថ្នាក់អនុបណ្ឌិត

- ភិក្ខុ **មួន វិចិត្រ** សមណនិស្សិតថ្នាក់អនុបណ្ឌិត

- ភិក្ខុ **ខ៉ាន នាគ** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ

- ភិក្ខុ **វ៉ា ចន្ទថន់** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ

- សាមណេរ **ឆ្លិច មាស** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ

- សាមណេរ **ឌិន ម៉ៅ** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ

- សាមណេរ **សុខ ធាវី** សមណនិស្សិតថ្នាក់បរិញ្ញាបត្រ

- ឧបាសក **ម៉ៅ វ៉ាន** និងឧបាសិកា **ឆន់ សំបូរ** អតីតទីប្រឹក្សាឯកអគ្គរាជទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា។

- លោក **ព្រំ ស៊ីណា** និស្សិតថ្នាក់បរិញ្ញាបត្រ

**អ្នករចនាក្រប**

- ភិក្ខុបញ្ញាវរោ **ស៊ុយ សុវណ្ណា**

**ការីកុំព្យូទ័រ**

- កញ្ញា **គុជ ស្រីអូន** បរិញ្ញាបត្ររដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យខេមរៈ

- សៀវភៅដែលខ្ញុំបានប្រែ និងបោះពុម្ពរួចហើយ៖

  ១. ជីវិតធម៌ បោះពុម្ព នៅឆ្នាំ២០០៣
  ២. ហេតុអ្វីយើងគប្បីប្រតិបត្តិតាមព្រះពុទ្ធសាសនា បោះពុម្ពនៅឆ្នាំ២០១១

- សៀវភៅដែលខ្ញុំបកប្រែរួចរាល់តែពុំទាន់បានបោះពុម្ព

  ១. គុកជីវិត
  ២. កាមសូត្រ
  ៣. ព្រះពុទ្ធនៅឯណា?

- សៀវភៅដែលនិពន្ធដោយស្នាដៃខ្ញុំផ្ទាល់ (ជាភាសាអង់គ្លេស)

  ១. Analytical Study of Anatta in Theory and Practice
  ២. How to Attain Supreme Happiness
  ៣. Buddhist View on Caste System